# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានអង្គការ **JETRO** ប្រចាំកម្ពុជាដែលទើបចប់អណត្តិ



នៅរសៀលថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Kiyotaka Doho** ប្រធានអង្គការពាណិជ្ជកម្មក្រៅស្រុកជប៉ុន (JETRO) ប្រចាំកម្ពុជា ដើម្បីសំដែងការគួរសម និងជម្រាបលា ក្នុងឱកាសដែលលោកត្រូវបានបញ្ចប់អណត្តិបេសកកម្មនៅកម្ពុជា ។ ដោយឡែក លោក **KONO Masashi** ដែលនឹងត្រូវមកកាន់តំណែងជំនួសលោក **Kiyotaka Doho** ក៏មានវត្តមានចូលរួមនាឱកាស នោះផងដែរ ។





ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងាររបស់អង្គការ JETRO ជប៉ុន នៅកម្ពុជា ដែលបានដើរតួយ៉ាងសំខាន់ ក្នុងការទាក់ទាញក្រុមហ៊ុនវិនិយោគជាច្រើនពីប្រទេសជប៉ុនមកបណ្តាក់ទុននៅកម្ពុជា ។ ម៉្យាងទៀតអង្គការ JETRO ក៏បានដើរតួជាស្ពានសម្រាប់តភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្ម រវាងកម្ពុជា និងជប៉ុន ក្នុងខណៈដែលប្រទេសជប៉ុនបានផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណដល់អង្គការ JETRO ដែលកន្លងមក បានរៀបចំសិក្ខាសាលា ក៏ដូចជាវេទិកា ជាច្រើន នៅទីក្រុងផ្សេងៗគ្នា នៃប្រទេសជប៉ុន ដែលបានផ្តល់ឱកាសឱ្យឯកឧត្តមផ្ទាល់ ក្នុងនាមជាអតីតៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការធ្វើបទឧទ្ទេសនាម បង្ហាញពីសក្តានុពល និងលក្ខណៈអំណោយផលនៃប្រទេសកម្ពុជា ជូនវិនយោគិន និងធុរៈជន នៃប្រទេសជប៉ុន ឱ្យមានការចាប់អារម្មណ៍បណ្តាក់ទុននៅកម្ពុជា ជាបន្តបន្ទាប់ ។



ជាមួយនិងមតិស្វាគមន៍ ចំពោះលោក **KONO Masashi** ដែលត្រូវបន្តតំណែងជាប្រធានអង្គការ JETRO ប្រចាំកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានជម្រាបពីលក្ខណៈអំណោយផលរបស់ប្រទេសកម្ពុជា ដែលទទួលបាននូវស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយសង្ឃឹមថា ប្រធានអង្គការ JETROថ្មី នឹងជួយទាក់ទាញបន្ថែមទៀតដល់វិនិយោគិនជប៉ុនមកកម្ពុជា ។

លោក **Kiyotaka Doho** ប្រធានអង្គការពាណិជ្ជកម្មក្រៅស្រុកជប៉ុន (JETRO) ប្រចាំកម្ពុជា ដែលទើបចប់អណត្តិ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដែលឯកឧត្តម បានគាំទ្រយ៉ាងខ្លាំង និងមានកិច្ចសហការដ៏ល្អជាមួយអង្គការ JETRO ដែលធ្វើឱ្យអង្គការនេះ សម្រេចបានជោគជ័យ ក្នុងបេសកកម្មការងាររបស់ខ្លួន ជាពិសេស គឺការជួយទាក់ទាញក្រុមហ៊ុនជប៉ុនជាច្រើនមកស្វែងយល់ និងវិនិយោគនៅកម្ពុជា ដែលមានប្រមាណជាង៧០០ក្រុមហ៊ុន ចាប់តាំងពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៤ នេះ ។ ម៉្យាងទៀត ការបង្កើតការិយាល័យអង្គការ JETRO នៅទីក្រុងភ្នំពេញ កាលពីខែមីនា ឆ្នាំ២០១០ កន្លងទៅ គឺមិនអាចកាត់ផ្តាច់ពីការជួយជ្រោមជ្រែង គាំទ្រ និងសហការយ៉ាងពេញទំហឹងពីឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ កាលឯកឧត្តមជាអតីតទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានឡើយ ។

ដោយឡែកលោក **KONO Masashi** ប្រធានអង្គការ JETRO ប្រចាំកម្ពុជាទើបតែងតាំងថ្មី បានសំដែងនូវទឹកចិត្តរីករាយ ចំពោះការបំពេញអណត្តិបេសកកម្មនៅកម្ពុជា ហើយនឹងខិតខំបន្ត និងជម្រុញទំនាក់ទំនងដ៏ល្អរវាងកម្ពុជា–ជប៉ុន ជាពិសេសលើវិស័យពាណិជ្ជកម្ម និងវិនិយោគ ។